ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍នេសាទ
# ចារុះ
## រយៈពេល ៣ឆ្នាំ (២០១៨ ដល់ ២០២០)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ ចារុះ |
| ភូមិ | ៖ ចារុះ |
| ឃុំ | ៖ រាំងទិល |
| ស្រុក | ៖ កណ្តៀង |
| ខេត្ត | ៖ ពោធិ៍សាត់ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ ចារុះ

## រយៈពេល ៣ឆ្នាំ (២០១៨ ដល់ ២០២០)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ ចារុះ |
| ភូមិ | ៖ ចារុះ |
| ឃុំ | ៖ រាំងទិល |
| ស្រុក | ៖ កណ្ដៀង |
| ខេត្ត | ៖ ពោធិ៍សាត់ |

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**១.ស្ថានភាពទូទៅ**

**២.អំពីប្រជាសាស្ត្រ**

ក.ប្រជាជន

ខ.មុខរបរ

**៣.កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍**

ក.ទីតាំង

ខ.ដែននេសាទ

គ.តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

**៤.ការធ្វើនេសាទ**

ក.អ្នកនេសាទ

ខ.ឧបករណ៍នេសាទ

គ.ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ

**៥.ផែនការគ្រប់គ្រងសហគមន៍នេសាទ**

ក.ទស្សនៈវិស័យ

ខ.គោលបំណង

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

គ២.ផែនការកែលំអដែននេសាទ

គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស

គ៤.ផែនការគ្រប់គ្រងនិងដាំព្រៃលិចទឹក

គ៥.ការផែនការអភិវឌ្ឍន៍វារីវប្បកម្ម

គ៦.ផែនការបណ្តុះបណ្តាល

គ៧.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ឃ.យុទ្ធសាស្ត្រ

-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ឆ្នាំ

-តារាងកម្មវិធីការងារ

-តារាងឧបសម្ព័ន្ធ

# ផែនការគ្រប់គ្រង
# តំបន់ការពារសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទចារុះ ត្រូវបានរៀបចំឡើងដោយបបាសន្និបាតកំណើតដំបូងនៅ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ បានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចុះថ្ងៃទី១៦ ខែ១០ ឆ្នាំ២០០៧ ។

សហគមន៍នេសាទចារុះ មានទីតាំងស្ថិតនៅក្នុងភូមិចារុះ ឃុំរាំងទិល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ដែលមានសមាជិកចំនួន២០៤នាក់ ស្រី៩៨នាក់ និងមានគណៈកម្មការចំនួន១១នាក់ ស្រី០២នាក់ ។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន៩៤គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ ខ្លួនរួមមាន៖

- លក្ខន្តិកៈសហគមន៍នេសាទ
- បទបញ្ជាផ្ទៃក្នុង
- បញ្ជីឈ្មោះសមាជិកសហគមន៍
- ចុះកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍
- ប្រមូលពត៌មានទូទៅសម្រាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ចូលរួមប្រជុំជាមួយភូមិ ឃុំ
- ចូលរួមដាំកូនឈើព្រៃលិចទឹក
- ចូលរួមអប់រំផ្សព្វផ្សាយ
- រៀបចំកន្លែងអភិរក្ស
- សហការជាមួយមេភូមិ និងក្រុមប្រឹក្សាឃុំ និងសហការជាមួយជំនាញជលផល
- ចុះល្បាតក្នុងដែនសហគមន៍នេសាទ។

## ២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន នាក់ស្រី ៤៧០នាក់ ប្រុស២០២នាក់ ក្នុងនោះមានជនជាតិខ្មែរ៤៦៣នាក់ ខ្មែរឥស្លាមចំនួន០នាក់ អាណិកជនវៀតណាមចំនួន៧នាក់។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន ៨នាក់
- ចំនួជនពិការក្នុងសហគមន៍នេសាទមានចំនួន ០នាក់ ស្រី ០នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន ៤នាក់ ស្រី០៣នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមានចំនួន ០នាក់ ស្រី ០នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន ០១នាក់ ស្រី ០នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%។

ក្រៅពីនេះមានអ្នកកាន់សាសនាឥស្លាមប្រមាណ០% និងសាសនាយេស៊ូប្រមាណ ០%។

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់មាន

- អ្នកមិនចេះអក្សរមានចំនួន ៦០នាក់ ស្រី ៣៦នាក់
- កំរិតថ្នាក់បឋមសិក្សាចំនួន ៤៤នាក់ ស្រី២៤នាក់
- កំរិតមធ្យមសិក្សាចំនួន ០នាក់ ស្រី០នាក់
- និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន ០នាក់ ស្រី០នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- ធ្វើនេសាទចំនួន ៩៤គ្រួសារ
- ធ្វើវារីវប្បកម្ម ៩០គ្រួសារ ទំហំ (៣មx៤មx១,៥ម ៣មx៦មx១,៥ម ៣មx៤មx១,៥ម)
- ជួញដូរផលនេសាទ ០៥គ្រួសារ
- ចិញ្ចឹមសត្វ ២០គ្រួសារ
- លក់ដូរ ១៥គ្រួសារ
- គ្រូបង្រៀន ០១នាក់
- ជាងម៉ាស៊ីន ០១នាក់
- កែច្នៃផលនេសាទ ៨គ្រួសារ

## ៣.តំបន់នេសាទសហគមន៍និងធនធានជលផលដែលមាននៅតំបន់នេសាទសហគមន៍

**ក.ទីតាំង**

កន្លែងនេសាទសហគមន៍ ចារុះ ជាកន្លែងដែននេសាទដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ៣ មានដែននេសាទតាម បឹងបួរ ព្រែក ថ្លុក និងតាមព្រៃលិចទឹក កន្លងមកសហគមន៍នេសាទចារុះ បានចូលរួមគ្រប់គ្រង ថែរក្សាការពារ អភិរក្ស និងអភិវឌ្ឍន៍ ធនធានជលផលប្រកបដោយចិរភាព។

កន្លែងនេសាទសហគមន៍ ចារុះ មានទំហំ ៣៥៣៦ហិចតា និងមានកំណត់និយាមការដូចចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងឡូត៍លេខ៣ និងបឹងទន្លេសាប
- ខាងត្បូងទល់នឹងសហគមន៍នេសាទដូនជ្រុំ របងរមាស សំរោងមុខយក្ស ត្រាំពៃរ និងទួលគូ
- ខាងកើតទល់នឹងសហគមន៍នេសាទកោះព្រែករាំងទិល
- ខាងលិចទល់នឹងសហគមន៍នេសាទក្អមសំណរ

**ខ.ដែននេសាទ**

កន្លែងនេសាទសហគមន៍ ចារុះ មានបឹងចំនួន២២ ព្រែកចំនួន០៣ ថ្លុកចំនួន៤

- ឈ្មោះបឹងទន្លសាប ទំហំ ៦៣៨.៦៩ហិកតា ធ្វើនេសាទ ពីខែ០៩ ខែ១២
- ឈ្មោះបឹងអក ទំហំ ១៥.៥៧ហិកតា ធ្វើនេសាទ ពីខែ០៨ ខែ១២

- ឈ្មោះបឹងស្រុតត្រុត ទំហំ ៦.៧៥ហិកតា ធ្វើនេសាទ ពីខែ០៦ ខែ០៣
- ឈ្មោះបឹងវែង ទំហំ ៦.៧០ហិកតា ធ្វើនេសាទ ពីខែ០១ ខែ១០
- ឈ្មោះបឹងកក់គរ ទំហំ ១២.១០ហិកតា ធ្វើនេសាទ ពីខែ០៦ ខែ០៣
- ឈ្មោះបឹងចក ទំហំ ៥.១២ហិកតា ធ្វើនេសាទ ពីខែ០៧ ខែ០១
- ឈ្មោះបឹងចងក្រពើ ទំហំ ១.៩៦ហិកតា ធ្វើនេសាទ ពីខែ០៩ ខែ១២
- ឈ្មោះបឹងទឹកថ្លា ទំហំ ០.០១ហិកតា ធ្វើនេសាទ ពីខែ០៧ ខែ០២
- ឈ្មោះបឹងកង ទំហំ ០.៥៦ហិកតា ធ្វើនេសាទ ពីខែ០៦ ខែ១២
- ឈ្មោះបឹងរាំង ទំហំ ០.៣៤ហិកតា ធ្វើនេសាទ ពីខែ០៦ ខែ០៣
- ឈ្មោះបឹងផ្តៅ ទំហំ ០.៦៨ហិកតា ធ្វើនេសាទ ពីខែ០៦ ខែ១០
- ឈ្មោះបឹងរូង ទំហំ ០.៩០ហិកតា ធ្វើនេសាទ ពីខែ០៦ ខែ១២
- ឈ្មោះបឹងកន្សែងក្រោម ទំហំ ១.១៧ហិកតា ធ្វើនេសាទ ពីខែ០៦ ខែ០៩
- ឈ្មោះបឹងកន្សែង ទំហំ ៣.៥៩ហិកតា ធ្វើនេសាទ ពីខែ០៦ ខែ០៣
- ឈ្មោះបឹងកន្សែងលើ ទំហំ ០.៨៤ហិកតា ធ្វើនេសាទ ពីខែ០៦ ខែ០៣
- ឈ្មោះបឹងទីសំណាប ទំហំ ០.៦៨ហិកតា ធ្វើនេសាទ ពីខែ០១ ខែ០៦
- ឈ្មោះបឹងរូងផ្តោល ទំហំ ០.២៤ហិកតា ធ្វើនេសាទ ពីខែ០១ ខែ០៥
- ឈ្មោះបឹងកំប៉ោង ទំហំ ០.៧១ហិកតា ធ្វើនេសាទ ពីខែ០១ ខែ០៦
- ឈ្មោះបឹងក្រពើរាល ទំហំ ០.៧៤ហិកតា ធ្វើនេសាទ ពីខែ០១ ខែ០៧
- ឈ្មោះបឹងព្រានស៊ីលៀស ទំហំ ០.២១ហិកតា ធ្វើនេសាទ ពីខែ០១ ខែ០៤
- ឈ្មោះបឹងរាំង ទំហំ ០.២២ហិកតា ធ្វើនេសាទ ពីខែ០១ ខែ០៣
- ឈ្មោះបឹងផ្តោល ទំហំ ០.៥៥ហិកតា ធ្វើនេសាទ ពីខែ០១ ខែ១០
- ឈ្មោះព្រែកចារុះ ទំហំ ២០មx៨០០០ម ធ្វើនេសាទ ពីខែ០១ ខែ០៦
- ឈ្មោះព្រែកទាល់កើត ទំហំ ៥០មx១០០០ម ធ្វើនេសាទ ពីខែ០១ ខែ១២
- ឈ្មោះព្រែកទាល់លិច ទំហំ ៥០មx១០០០ម ធ្វើនេសាទ ពីខែ០១ ខែ១២
- ព្រៃលិចទឹកមានទំហំសរុប ទំហំ ២៦២៥.៦៨ហិកតា
- ដីទំនាបលិចទឹកមានទំហំសរុប ១៩១.៨៤ហិកតា។

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- ១ ព្រែកទាល់ខាងកើត ទំហំ ៥ហិកតា ( ៥០មx១០០០ម)

**ឃ.ធនធានជលផល**

- ប្រភេទត្រី (ត្រីរ៉ស់ ឆ្តោ ផ្ទក់ ត្រីព្រួល ត្រីប្រា ត្រីក្រាយ ត្រីឆ្លាំង ត្រីកេស ត្រីឆ្តោក ត្រីក្អែក ត្រីក្រសក់ ត្រីគល់រាំង ត្រីកញ្ចុះ ត្រីក្រាញ់ ត្រីរៀល ត្រីចង្វា ត្រីឆ្លូញ ត្រីពោធិ៍ ត្រីដំរី ត្រីតាអោន ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ទ្រប់ ត្រីលេញ ត្រីខ្លាំងហាយ ត្រីឆ្ពិន ត្រីគ្រំ ត្រីប្រម៉ា ត្រីកន្លង់ ត្រីធៀត ត្រីកញ្ជ្រូក ត្រីកាហែ ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស ត្រីបណ្តូលអំពៅ ត្រីក្បក ត្រីអណ្តាផ្លែ ត្រីច្រកែង ត្រីប្រម៉ា ត្រីអង្កត់ប្រាក់........... )

- **ប្រភេទវារីសត្វ** (អណ្តើក ឆ្មារដាវ កង្កែប កន្ធាយ ពស់ អន្ទង់ ក្អែកទឹក ក្រសា ភេ មាន់ទឹក ទោម កុក ក្តាម ខ្ចៅ ខ្យង លៀស គ្រំ។ល។
- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ** ( ដើមកន្សែង ដើមទន្លា កក់ជ្រុក កក់ក្តាម ឈូក ចន្ទល់ភ្នំ ត្រាវអណ្តែត សណ្តាន់ ដើមម្តេញ ដើមត្រឡក ដើមសន្ទៃ ដើមខ្ញុំ ដើមសង្ឃរ សារាយសាបរាំង ក្រស់ ត្នួរ ព្រលិត ត្រកួន វិចង់ ថ្លើមអណ្តើក បន្លាស្អិត ប្របួយមេ ប្របួយឈ្មោល ភ្នំភ្លែង សណ្តាន់ ដើមរំពាក់ ដើមម្តេញ ដើមដៃខ្លា វល្លិ៍ក្អើក ស្លាបទា កំប្លោក ចកបាយទា កំពីងពួយស កំពីពួយក្រហម កក់ជ្រុង សារាយ កញ្ឆែត ស្មៅថ្នក់ទឹក ចំប្លង។ល។

## ៤. ការធ្វើនេសាទ

### ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍ នេសាទមានចំនួន ២០៤នាក់ ស្រី៩៨នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៤០នាក់ ស្រី១០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន១៥០នាក់ ស្រី២៥នាក់

### ខ.ឧបករណ៍នេសាទ

**ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ៖**

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ (ជាមធ្យម/គ្រួសារ) | ទំហំ/ប្រវែង | រដូវប្រើប្រាស់ ឧបករណ៍ |
|---|---|---|---|---|---|
| មងរាយ មងបណ្តែត | ម៉ែត្រ (១ដៃ=៨០ម) | ៥០ | ១០ដៃ/គ្រួសារ | ចំនួន=៤០០០០ម ក្រឡា=០,០២ម-០,០៥ ម | ខែ០១ ដល់ ខែ១២ |
| សន្ទូចរនង | ផ្លែ | ១០ | ១០០០ផ្លែ/នាក់ | ចំនួន=១០០០០ផ្លែ | ខែ០៦ ដល់ ខែ០២ |
| លប | គ្រឿង | ២ | ៤០គ្រឿង/នាក់ | ចំនួន=៨០គ្រឿង កំពស់=១,៨ម មុខកាត់=០,៦ម | ខែ០៦ ដល់ ខែ០២ |
| លាន់ | គ្រឿង | ១ | ៣០គ្រឿង/គ្រួសារ | ៣០គ្រឿង មុខកាត់=០,០៨ម ប្រវែង=២ម. | ខែកក្កដា ដល់ ខែធ្នូ |
| កន្ទុំកំពិស | គ្រឿង | ៦ | ២០០គ្រឿង/គ្រួសារ | ១២០០គ្រឿង មុខកាត់=០,៣ម ប្រវែង=០,៧ម | ខែ០២ ដល់ ខែ០៦ |
| ឡើ | គ្រឿង | ១២ | ២០គ្រឿង/គ្រួសារ | ២៤០គ្រឿង មុខកាត់=០,៤ម ប្រវែង=០,៦ម | ខែ១០ ដល់ ខែ០២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេស |
|---|---|---|---|
| ទូកចែវ | ១០គ្រឿង | ១០០គក្រ-៣០០គក្រ | |
| កាណូត | ២០៤គ្រឿង | ៥០០គក្រ-២០០០គក្រ | ៣.៥សេស - ៣៥សេស |

ឧបករណ៍នេសាទនិងទូករបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ (ជាមធ្យម/គ្រួសារ) | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មងរាយ មងបណ្តែត | ម៉ែត្រ (១ដៃ=៨០ម) | ១០ | ១០ដៃ/គ្រួសារ | ចំនួន=៨០០០ម ក្រឡា=០,០២ម-០,០៥ ម | ខែ០១ ដល់ ខែ១២ |
| សន្ទូចរនង | ផ្លែ | ២ | ១០០០ផ្លែ/នាក់ | ចំនួន=២០០០ផ្លែ | ខែ០៦ ដល់ ខែ០២ |
| លប | គ្រឿង | ១ | ៤០គ្រឿង/នាក់ | ចំនួន=៤០គ្រឿង កំពស់=១,៨ម មុខកាត់=០,៦ម | ខែ០៦ ដល់ ខែ០២ |
| លាន់ | គ្រឿង | ១ | ៣០គ្រឿង/គ្រួសារ | ៣០គ្រឿង មុខកាត់=០,០៨ម ប្រវែង=២ម. | ខែកក្កដា ដល់ ខែធ្នូ |
| កន្ទុំកំពិស | គ្រឿង | ៣ | ២០០គ្រឿង/គ្រួសារ | ៦០០គ្រឿង មុខកាត់=០,៣ម វែង=០,៧ម | ខែ០២ ដល់ ខែ០៦ |
| ទ្បើ | គ្រឿង | ៣ | ២០គ្រឿង/គ្រួសារ | ៦០គ្រឿង មុខកាត់=០,៤ម ប្រវែង=០,៦ម | ខែ១០ ដល់ ខែ០២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេស |
|---|---|---|---|
| ទូកចែវ | ២គ្រឿង | ១០០គក្រ-៣០០គក្រ | |
| កាណូត | ១៣គ្រឿង | ៥០០គក្រ-២០០០គក្រ | ៣.៥សេស - ៣៥សេស |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាជិកដែលមកពីខាងក្រៅសហគមន៍នេសាទ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ (ជាមធ្យម/គ្រួសារ) | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មងរាយ មងបណ្តែត | ម៉ែត្រ (១ដៃ=៨០ម) | ៣០ | ១០ដៃ/គ្រួសារ | ចំនួន=២៤០០០ម ក្រឡា=០,០២ម-០,០៥ ម | ខែ០១ដល់ ខែ១២ |
| សន្ទូចរនង | ផ្លែ | ១៥ | ១០០០ផ្លែ/នាក់ | ចំនួន=១៥០០០ផ្លែ | ខែ០៦ដល់ ខែ០២ |
| លប | គ្រឿង | ៣ | ៤០គ្រឿង/នាក់ | ចំនួន=១២០គ្រឿង កំពស់=១,៨ម មុខកាត់=០,៦ម | ខែ០៦ដល់ ខែ០២ |
| លាន់ | គ្រឿង | ២ | ៦០គ្រឿង/គ្រួសារ | ៣០គ្រឿង មុខកាត់=០,០៨ម ប្រវែង=២ម. | ខែ០៧ដល់ ខែ១២ |
| កន្ទុំកំពិស | គ្រឿង | ៤ | ២០០គ្រឿង/គ្រួសារ | ៨០០០គ្រឿង មុខកាត់=០,៣ម ប្រវែង=០,៧ម | ខែ០២ដល់ ខែ០៦ |
| ទ្បើ | គ្រឿង | ៨ | ២០គ្រឿង/គ្រួសារ | ១៦០គ្រឿង មុខកាត់=០,៤ម ប្រវែង=០,៦ម | ខែ១០ដល់ ខែ០២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេស |
|---|---|---|---|
| ទូកចែវ | ៥គ្រឿង | ១០០គក្រ-៣០០គក្រ | |
| កាណូត | ១២០គ្រឿង | ៥០០គក្រ-២០០០គក្រ | ៣.៥សេស - ៣៥សេស |

## ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទឧបករណ៍ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជាគក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ១.៥៣០គក្រ | ៧៧៤គក្រ | ២.៣០៤គក្រ |
| បង្គា/កំពិស | ៤០០គក្រ | ២៥០គក្រ | ៦៥០គក្រ |
| អន្ទង់ | 0 | ១២០គក្រ | ១២០គក្រ |
| សរុប | | | ៣.០៧៤គក្រ |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទ ចារុះ មានទស្សនៈវិស័យចូលរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

ចង់ឲ្យសមាជិកសហគមន៍នេសាទមានការចូលរួមបង់បដិភាគ និងមានការចូលរួមបង់វិភាគទាន ពីអ្នកខាងក្រៅក្នុងការរួមចំណែកការពារ និងគ្រប់គ្រងធនធានធម្មជាតិឲ្យមាននិរន្តភាព។

សហគមន៍មានកន្លែងអភិរក្ស សម្រាប់បង្កើតកន្លែងទេសចរណ៍ធម្មជាតិ ដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់ធ្វើការអភិវឌ្ឍន៍សហគមន៍ឲ្យមាននិរន្តរភាព ។

ចូលរួមគ្រប់គ្រង និងថែរក្សាការពារធនធានធម្មជាតិ សម្រាប់រក្សាទុកឲ្យប្រជានេសាទ រកជាលក្ខណៈគ្រួសារដោយបែងចែកផលប្រយោជន៍ ធនធានជលផលប្រកបដោយសមធម៌ និងធ្វើឲ្យប្រសើរឡើងនូវជីវភាព។

ចង់ឲ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្បាស់ និងចូលរួមការពារធនធានធម្មជាតិ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានជលផល។

មានការចូលរួមសហការ និងគាំទ្រពីអាជ្ញាធរ ព្រមទាំងមន្ត្រីជំនាញ ក្នុងការអន្តរាគមន៍បទល្មើសនិងដោះស្រាយបញ្ហាផ្សេងៗនៅក្នុងសហគមន៍។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

**ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖**

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតិឲ្យប្រើ | | |
|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន |
| -បឹងទន្លេសាប | ខែ០១ ដល់ ខែ១២ | មង | ប្រវែងមិនលើសពី៥០០ម/ម្នាក់<br>ក្រឡា=២,៥-៤,៥ ស ម ,ជម្រៅ=១,៥ ម | ១៨៥នាក់ |

| | | | | |
|---|---|---|---|---|
| | ខែ០៦ ដល់ ខែ០២ | សន្ទូចរនង | ចំនួនមិនលើសពី ១០០០ផ្លែ/ម្នាក់<br>(លេខ១២,១៣) | ៥០នាក់ |
| | ខែ០២ ដល់ ខែ០៦ | កន្សុំកំពិស | ២០០គ្រឿង/គ្រួសារ<br>មុខកាត់០,៣មxប្រវែង០,៧ម | ៨គ្រួសារ |
| | ខែ០១ ដល់ ខែ១២ | សំណាញ់ | ១វង់/គ្រួសា<br>ប្រវែង ៦មxក្រលា ០,០២៥ម | ៦០គ្រួសារ<br>៦០វង់ |
| | ខែ១០ ដល់ ខែ០២ | ឡើ | ចំនួនមិនលើសពី ៤៥គ្រឿង/ម្នាក់<br>មុខកាត់០,៤មxកំពស់០,៦ម | ២៥គ្រួសារ |
| | ខែ០១ ដល់ ខែ១២ | ថ្នង | ១គ្រឿង/គ្រួសារ<br>២,៥x៣មx០,០១៥ម | ៨នាក់<br>៨គ្រឿង |
| | ខែ០៦ ដល់ ខែ០២ | លប | ចំនួនមិនលើសពី៤០គ្រឿ/ម្នាក់<br>មុខកាត់០,៦មxកំពស់១,៨ម(របាំងព្រួល៥ម) | ១២នាក់<br>១២គ្រឿង |
| | ខែ០១ ដល់ ខែ១២ | អួន | ១វង់/គ្រួសារ<br>ប្រវែងមិនលើសពី១២០ម<br>ក្រលាចាប់ពី០,០២៥ម | ៣០គ្រួសារ<br>៣០វង់ |
| | ខែ០៧ ដល់ ខែ១២ | លាន់ | មិនលើសពី១០០គ្រឿង/គ្រួសារ<br>មុខកាត់០,០៨មxប្រវែង២ម | ១០នាក់ |
| -បឹងអក<br>-បឹងកក់តរ | ខែ០១ ដល់ ខែ១២ | មង | ប្របវែងមិនលើសពី៤០០ម/ម្នាក់<br>ក្រឡា=២,៥-៤,៥ ស ម ,ជម្រៅ=១,៥ ម | ៨០នាក់ |
| | ខែ០៦ ដល់ ខែ០២ | សន្ទូចរនង | ចំនួនមិនលើសពី ៨០០ផ្លែ/ម្នាក់<br>(លេខ១២,១៣) | ២០នាក់ |
| | ខែ០២ ដល់ ខែ០៦ | កន្សុំកំពិស | ២០០គ្រឿង/គ្រួសារ<br>មុខកាត់០,៣មxប្រវែង០,៧ម | ៥គ្រួសារ |
| | ខែ០១ ដល់ ខែ១២ | សំណាញ់ | ១វង់/គ្រួសា<br>ប្រវែង ៦មxក្រលា ០,០២៥ម | ៣៥គ្រួសារ<br>៣៥វង់ |
| | ខែ១០ ដល់ ខែ០២ | ឡើ | ចំនួនមិនលើសពី ៤០គ្រឿង/ម្នាក់<br>មុខកាត់០,៤មxកំពស់០,៦ម | ១៥គ្រួសារ |
| | ខែ០១ ដល់ ខែ១២ | ថ្នង | ១គ្រឿង/គ្រួសារ<br>២,៥x៣មx០,០១៥ម | ១០គ្រួសារ |
| | ខែ០៦ ដល់ ខែ០២ | លប | ចំនួនមិនលើសពី៣០គ្រឿ/ម្នាក់<br>មុខកាត់០,៦មxកំពស់១,៨ម(របាំងព្រួល៥ម) | ១៥នាក់ |
| | ខែ០១ ដល់ ខែ១២ | អួន | ១វង់/គ្រួសារ<br>ប្រវែងមិនលើសពី១០០ម<br>ក្រលាចាប់ពី០,០២៥មឡើងទៅ | ៦គ្រួសារ<br>៦វង់ |
| | ខែ០៧ ដល់ ខែ១២ | លាន់ | មិនលើសពី១០០គ្រឿង/គ្រួសារ<br>មុខកាត់០,០៨មxប្រវែង២ម | ៤នាក់ |
| -បឹងស្រុតត្រុត<br>-បឹងវែង | ខែ០១ ដល់ ខែ១២ | មង | ប្របវែងមិនលើសពី៣២០ម/ម្នាក់<br>ក្រឡា=២,៥-៤,៥ ស ម ,ជម្រៅ=១,៥ ម | ៧៥នាក់ |

| | | | | |
|---|---|---|---|---|
| -បឹងចក<br>-បឹងកន្សែង | ខែ០៦ ដល់ ខែ០២ | សន្ទូចរនង | ចំនួនមិនលើសពី ៨០០ផ្លែ/ម្នាក់<br>(លេខ១២,១៣) | ១៨នាក់ |
| | ខែ០២ ដល់ ខែ០៦ | កន្ទុំកំពិស | ២០០គ្រឿង/គ្រួសារ<br>មុខកាត់០,៣មxប្រវែង០,៧ម | ៣គ្រួសារ |
| | ខែ០១ ដល់ ខែ១២ | សំណាញ់ | ១វង់/គ្រួសា<br>ប្រវែង ៦មxក្រលា ០,០២៥ម | ២៨គ្រួសារ<br>២៨វង់ |
| | ខែ១០ ដល់ ខែ០២ | ឡើ | ចំនួនមិនលើសពី ៤០គ្រឿង/ម្នាក់<br>មុខកាត់០,៤មxកំពស់០,៦ម | ១៥គ្រួសារ |
| | ខែ០១ ដល់ ខែ១២ | ថ្នង | ១គ្រឿង/គ្រួសារ<br>២,៥x៣មx០,០១៥ម | ៨គ្រួសារ |
| | ខែ០៦ ដល់ ខែ០២ | លប | ចំនួនមិនលើសពី២៥គ្រឿ/ម្នាក់<br>មុខកាត់០,៦មxកំពស់១,៨ម(របាំងព្រួល៥ម) | ២០នាក់ |
| | ខែ០១ ដល់ ខែ១២ | អួន | ១វង់/គ្រួសារ<br>ប្រវែងមិនលើសពី១០០ម<br>ក្រលាចាប់ពី០,០២៥មឡើងទៅ | ៥គ្រួសារ<br>៥វង់ |
| | ខែ០៧ ដល់ ខែ១២ | លាន់ | មិនលើសពី៨០គ្រឿង/គ្រួសារ<br>មុខកាត់០,០៨មxប្រវែង២ម | ៥នាក់ |
| -បឹងកន្សែងក្រោម<br>-បឹងចងក្រពើ | ខែ០៦ ដល់ ខែ១២ | មង | ប្របវែងមិនលើសពី២៤០ម/ម្នាក់<br>ក្រឡា=២,៥-៤,៥ ស ម ,ជម្រៅ=១,៥ ម | ៥០នាក់ |
| | | សន្ទូចរនង | ចំនួនមិនលើសពី ៦០០ផ្លែ/ម្នាក់<br>(លេខ១២,១៣) | ១៨នាក់ |
| | | កន្ទុំកំពិស | ២០០គ្រឿង/គ្រួសារ<br>មុខកាត់០,៣មxប្រវែង០,៧ម | ៣គ្រួសារ |
| | | សំណាញ់ | ១វង់/គ្រួសា<br>ប្រវែង ៦មxក្រលា ០,០២៥ម | ២០គ្រួសារ<br>២០វង់ |
| | | ឡើ | ចំនួនមិនលើសពី ៣០គ្រឿង/ម្នាក់<br>មុខកាត់០,៤មxកំពស់០,៦ម | ១៥គ្រួសារ |
| | | ថ្នង | ១គ្រឿង/គ្រួសារ<br>២,៥x៣មx០,០១៥ម | ៦គ្រួសារ |
| | | លប | ចំនួនមិនលើសពី២០គ្រឿ/ម្នាក់<br>មុខកាត់០,៦មxកំពស់១,៨ម(របាំងព្រួល៥ម) | ១៥នាក់ |
| | | អួន | ១វង់/គ្រួសារ<br>ប្រវែងមិនលើសពី១០០ម<br>ក្រលាចាប់ពី០,០២៥មឡើងទៅ | ៣គ្រួសារ<br>៣វង់ |
| | | លាន់ | មិនលើសពី៦០គ្រឿង/គ្រួសារ<br>មុខកាត់០,០៨មxប្រវែង២ម | ៤នាក់ |
| -បឹងទឹកថ្លា<br>-បឹងកង | ខែ០៦ ដល់ ខែ១២ | មង | ប្របវែងមិនលើសពី១៨០ម/ម្នាក់<br>ក្រឡា=២,៥-៤,៥ ស ម ,ជម្រៅ=១,៥ ម | ២០នាក់ |

| | | | | |
|---|---|---|---|---|
| -បឹងរាំង<br>-បឹងផ្តៅ<br>-បឹងរុង<br>-បឹងកន្សែងលើ<br>-បឹងទីសំណាប<br>-បឹងផ្តោល | | សន្ទូចរនង | ចំនួនមិនលើសពី ៥០០ផ្លែ/ម្នាក់<br>(លេខ១២,១៣) | ១០នាក់ |
| | | កន្សុំកំពិស | ២០០គ្រឿង/គ្រួសារ<br>មុខកាត់០,៣មxប្រវែង០,៧ម | ២គ្រួសារ |
| | | សំណាញ់ | ១វង់/គ្រួសា<br>ប្រវែង ៦មxក្រលា ០,០២៥ម | ១០គ្រួសារ<br>១០វង់ |
| | | ឡើ | ចំនួនមិនលើសពី ១៥គ្រឿង/ម្នាក់<br>មុខកាត់០,៤មxកំពស់០,៦ម | ១២គ្រួសារ |
| | | ថ្នង | ១គ្រឿង/គ្រួសារ<br>២,៥x៣មx០,០១៥ម | ៥គ្រួសារ |
| | | លប | ចំនួនមិនលើសពី១៥គ្រឿ/ម្នាក់<br>មុខកាត់០,៦មxកំពស់១,៨ម(របាំងព្រួល៥ម) | ៩នាក់ |
| | | អួន | ១វង់/គ្រួសារ<br>ប្រវែងមិនលើសពី១០០ម<br>ក្រលាចាប់ពី០,០២៥មឡើងទៅ | ២គ្រួសារ<br>២វង់ |
| | | លាន់ | មិនលើសពី៥០គ្រឿង/គ្រួសារ<br>មុខកាត់០,០៨មxប្រវែង២ម | ៤នាក់ |
| -ព្រែកចារុះ<br>-ព្រែកទាល់លិច | ខែ០១ ដល់ ខែ១២ | មង | ប្រវែងមិនលើសពី៣២០ម/ម្នាក់<br>ក្រឡា=២,៥-៤,៥ ស ម ,ជម្រៅ=១,៥ ម | ៧០នាក់ |
| | ខែ០៦ ដល់ ខែ០២ | សន្ទូចរនង | ចំនួនមិនលើសពី ១០០០ផ្លែ/ម្នាក់<br>(លេខ១២,១៣) | ២០នាក់ |
| | ខែ០២ ដល់ ខែ០៦ | កន្សុំកំពិស | ២០០គ្រឿង/គ្រួសារ<br>មុខកាត់០,៣មxប្រវែង០,៧ម | ៦គ្រួសារ |
| | ខែ០១ ដល់ ខែ១២ | សំណាញ់ | ១វង់/គ្រួសា<br>ប្រវែង ៦មxក្រលា ០,០២៥ម | ២៦គ្រួសារ<br>២៦វង់ |
| | ខែ១០ ដល់ ខែ០២ | ឡើ | ចំនួនមិនលើសពី ៤០គ្រឿង/ម្នាក់<br>មុខកាត់០,៤មxកំពស់០,៦ម | ១២គ្រួសារ |
| | ខែ០១ ដល់ ខែ១២ | ថ្នង | ១គ្រឿង/គ្រួសារ<br>២,៥x៣មx០,០១៥ម | ៦គ្រួសារ |
| | ខែ០៦ ដល់ ខែ០២ | លប | ចំនួនមិនលើសពី២៥គ្រឿ/ម្នាក់<br>មុខកាត់០,៦មxកំពស់១,៨ម(របាំងព្រួល៥ម) | ១៨នាក់ |
| | ខែ០១ ដល់ ខែ១២ | អួន | ១វង់/គ្រួសារ<br>ប្រវែងមិនលើសពី១០០ម<br>ក្រលាចាប់ពី០,០២៥មឡើងទៅ | ៥គ្រួសារ<br>៥វង់ |
| | ខែ០៧ ដល់ ខែ១២ | លាន់ | មិនលើសពី៨០គ្រឿង/គ្រួសារ<br>មុខកាត់០,០៨មxប្រវែង២ម | ៨នាក់ |

### គ.២ ផែនការកែលំអរដែននេសាទ

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាង ខាងក្រោម ៖

| ឈ្មោះ/ទីតាំង | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ/ខែ / ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ព្រែកទាល់កើត | ៥០មx១០០០ម | ៥០មx៥០០ម | ១. ស្វែងរកម្ចាស់ជំនួយ<br>២. សិក្សាទីតាំងនិងកំណត់ពេលស្តារ<br>៣. ចាប់ផ្តើស្តារ | ២០១៨ | ២០២០ |

### គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ព្រែកទាល់កើត | ៥០មx១០០០ម | រក្សាមេពូជត្រី | • ស្វែងរកម្ចាស់ជំនួយ<br>• បោះបង្គោលព្រំ១២ដើម<br>• ដាក់ស្លាកសញ្ញាចំនួន៤<br>• ដាក់ជម្រកសិប្បនិម្មិត<br>• រោងយាមចំនួន ១<br>• ចុះល្បាតជាប្រចាំ | ២០១៨ | ២០២០ |

### គ.៤ ផែនការគ្រប់គ្រង និងដាំព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ១.ដាំព្រៃលិចទឹកជុំវិញកន្លែងអភិរក្ស ព្រែកទាល់កើត ចំនួន២០០០ដើម | ៥ ហិកតា | រាំង,ក្រស់,ចង្កេង ផ្តោល ត្នួរ សណ្តាន់ | • ប្រជុំផ្សព្វផ្សាយ<br>• ស្វែងរកអ្នកជួយឧបត្ថម្ភ<br>• ដាំកូនឈើ<br>• បោះបង្គោលព្រំ ១០<br>• ដាក់ស្លាកសញ្ញាចំនួន៤<br>•ថែរក្សាការពារ | ២០០<br><br>១០០០០<br>១៣០០<br>៨០០ | ២០១៨ | ២០២០ |

### គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីក្នុងបែ | | | | | |

| | | | | | |
|---|---|---|---|---|---|
| -ជ្រើសរើសអ្នកស្ម័គ្រចិត្ត<br>-របៀបជ្រើសពូជត្រីចិញ្ចឹម<br>-ចំនួនត្រីដែលត្រូវចិញ្ចឹម<br>-របៀបអោយចំណី<br>-របៀបថែរក្សា និព្យាបាល<br>-ពេលវេលាសមស្របក្នុងការប្រមូលផល | -គណៈកម្មការ និងសមាជិកសហគមន៍នេសាទមានការយល់ដឹងពីបច្ចេកទេសចិញ្ចឹម ថែរក្សានឹងព្យាបាល<br>-កាត់បន្ថយសំពាធការនេសាទត្រីពីធម្មជាតិ<br>-មានមុខរបរបន្ថែមដើម្បីបង្កើនប្រាក់ចំណូល | ៣.០០០ | គណៈកម្មការសមាជិកស.ន | ២០១៨ | ២០២០ |

## គ.៦-ផែនការបណ្តុះបណ្តាល

ផែនការបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ ដូចមានខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រ មាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការបណ្តុះបណ្តាល | | | | | |
| បណ្តុះបណ្តាលស្តីពីរបៀប<br>-រៀបចំលិខិតរដ្ឋបាល<br>-សរសេររបាយការណ៍<br>-សរសេរកំណត់ហេតុ<br>-ជំនាញសម្របសម្រួល<br>-ជំនាញដោះស្រាយទំនាស់ក្នុងសហគមន៍ | -គណៈសហគមន៍នេសាទយល់ដឹងពីរបៀបរបបធ្វើការងារ<br>-ទំនាស់ទាំងឡាយដែលកើតមានក្នុងសហគមន៍នឹងត្រូវកាត់បន្ថយដោយគ្មានអំពើហឹង្សា | ២.៥០០ | -គណៈកម្មការ-សមាជិកស.ន<br>-អាជ្ញាធរមូលដ្ឋាន | ២០១៨ | ២០២០ |

## គ.៧- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន១០០០៛/ម្នាក់ | ខែមករា/២០១៨ | ខែធ្នូ/២០២០ | ២០៤.០០០៛ | ម្តង/ឆ្នាំ<br>រៀងរាល់ ខែមករា ចាប់ពីឆ្នាំ២០១៨ - ២០២០ អនុវត្តតាមលក្ខន្តិកៈ |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ ២០០០៛/ម្នាក់ | ឆ្នាំ២០១៨ | ឆ្នាំ២០២០ | ១.២២៤.០០០៛ | រយៈពេល ៣ឆ្នាំ |
| ប្រាក់ចំណូលពីអ្នក | -ផ្សព្វផ្សាយជូនដំណឹងនេសាទក្នុង | មករា/២០១៨ | ធ្នូ/២០២០ | | រយៈពេល ៣ឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| នេសាទក្នុងតំបន់ប៉ុន្តែ មិនមែនជាសមាជិក សហគមន៍ បង់ភាគទានអាជីវកម្មនេសាទ | តំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍<br>បង់ប្រាក់ភាគទាននេសាទ<br>-ប្រមូលភាគទាននេសាទ ៨០០០៛/ម្នាក់ | | | | |
| ប្រាក់ចំណូលពីអ្នកនេសាទមកពីខាងក្រៅបង់ភាគទានអាជីវកម្មនេសាទ | ផ្សព្វផ្សាយជូនដំណឹងនេសាទមកពីខាងក្រៅបង់ភាគទានអាជីវកម្មនេសាទ ៨០០០៛/ម្នាក់ | មករា/២០១៨ | ធ្នូ/២០២០ | | |

## ឃ.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការអោយទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានៈ

- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាល និងខណ្ឌរដ្ឋជលផល អាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងអង្គការនានាដើម្បីជួយផ្តល់យោបល់ចំពោះផែនការផ្សេងៗ ទាក់ទងនឹងបច្ចេកទេស ការរៀបចំកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងព្រៃលិចទឹក ការស្តារបឹង ព្រែក ស្រះ ការប្រើប្រាស់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់សហគមន៍ជាដើម។ល។
- រៀបចំផែនការ សម្រាប់ទំនាក់ទំនងស្វែងរកចំណូល តាមរយៈសមាជិកសហគមន៍ អ្នកនេសាទមកពីខាងក្រៅនិងតាមរយៈសម្បុរសធម៌ អង្គការនានា ផែនការវិនិយោគឃុំ ព្រមទាំងម្ចាស់ជំនួយផ្សេងៗ ដើម្បីគាំទ្រសហគមន៍។
- លើកផែនការ និងតម្រូវការរបស់សហគមន៍ បញ្ចូលជាមួយផែនការវិនិយោគឃុំ ប្រចាំឆ្នាំ ដោយជាក់លាក់ដែលមានការចូលរួមពីសមាជិកសហគមន៍។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- គៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ ជាពិសេសក្រុមយុវវ័យ និងរៀបចំវិធានការចំពោះអ្នកមិនមែនជាសមាជិកសហគមន៍ និងអ្នកនេសាទមកពីខាងក្រៅ។
- ពង្រឹងសមត្ថភាព បច្ចេកទេស និងការគ្រប់គ្រងភាពជាអ្នកដឹកនាំ ព្រមទាំងសិទ្ធិតួនាទី ដល់គណៈកម្មការក្រុមល្បាត និងសមាជិកសហគមន៍នេសាទ។
- បង្កើតឲ្យមានគោលការណ៍ ប្រើប្រាស់ថវិកា ក្នុងការចំណាយចំណូលនៅក្នុងសហគមន៍ដែលមានការកំណត់សិទ្ធិ នៃការចំណាយទម្រង់ការប្រើប្រាស់ថវិកាដើម្បីឲ្យមានតម្លាភាព ។
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

# តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ចារុះរយៈពេល ៣ ឆ្នាំ (២០១៨-២០២០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | • ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទ | • សំបូរត្រីឡើងវិញ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | ៣០០ដុល្លា | អង្គការដៃគូ | ចុងខែ០៥ រៀងរាល់ឆ្នាំ | ចុងខែ០៥ រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ |
| | • ត្រួតពិនិត្យនិងតាមដានលើការប្រើប្រាស់ឧបករណ៍នេសាទ | • សហគមន៍និងអ្នកនេសាទទាំងអស់អនុវត្តន៍តាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ | | | | | |
| ២.ផែនការកែលម្អដែននេសាទព្រែកទាល់កើត | • ស្វែងរកម្ចាស់ជំនួយ<br>• សិក្សាទីតាំងនិងទំហំដីដែលត្រូវស្តារ<br>• ចាប់ផ្តើមអនុវត្តស្តារដី ទំហំ ៥០មX១០០មX១,៥ម=៧៥០០ម៣ | • ដែននេសាទនឹងត្រូវបានកែលម្អពីភាពរីងស្ងួតទៅជាកន្លែងដែលមានទឹកគ្រប់គ្រាន់គ្រប់រដូវ<br>• បង្កើនធនធានជលផលទាំងវារីសត្វ និងវារីរុក្ខជាតិ | ១១.២៥០ ដុល្លា (១ម៣=១,៥$) ១ម៉ោង=៧៥$ | អង្គការដៃគូ | ០៣/២០១៨<br>០៣/២០១៩<br>០៣/២០២០ | ០៤/២០១៨<br>០៤/២០១៩<br>០៤/២០២០ | |
| ៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សព្រែកទាល់កើត | • ស្វែងរកម្ចាស់ជំនួយ<br>• បោះបង្គោលព្រំ១២ដើម<br>• ដាក់ស្លាកសញ្ញាចំនួន៤<br>• ដាក់ជម្រកត្រីសិប្បនិម្មិត<br>•សាងសង់ស្នាក់ការល្បាត<br>• ល្បាតប្រចាំការនៅកន្លែងអភិរក្ស | • ប្រភេទត្រីពូជសំខាន់ៗត្រូវបានអភិរក្ស<br>• ប្រជាជនបានយល់ដឹងនិងចូលរួមថែរក្សាកន្លែងអភិរក្ស<br>• កន្លែងអភិរក្សត្រូវបានរៀបចំឡើងនិងមានព្រំប្រទល់ច្បាស់លាស់<br>• បទល្មើសនេសាទត្រូវបានកាត់បន្ថយ | ១០.១០០ ដុល្លា | អង្គការដៃគូ | ២០១៨ | ២០២០ | |
| ៤.ផែនការដាំព្រៃលិចទឹកនៅជុំវិញកន្លែងអភិរក្សព្រែកទាល់កើតទំហំ៥ហិចតា | • ប្រជុំផ្សព្វផ្សាយ<br>• ស្វែងរកអ្នកជួយឧបត្ថម្ភ | • ព្រៃលិចទឹកដែលបាត់បង់ត្រូវមានឡើងវិញ<br>• ប្រជាពលរដ្ឋយល់ដឹងពីសារៈសំខាន់ព្រៃលិចទឹក<br>• បង្កើន វារីសត្វ រុក្ខជាតិ គ្រប់ប្រភេទ<br>• មានជម្រកសម្រាប់ត្រីពងកូន<br>• ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ | ២០០ដុល្លា | -អង្គការដៃគូ<br>-សហគមន៍ | ខែ០១/២០១៨ | ខែ០១/២០១៨ | |
| | • ដាំកូនឈើចំនួន ២០០០០ដើម | | ១០០០០ដុល្លា | | ខែ០៦/២០១៨ | ខែ០៦/២០១៨ | |
| | • បោះបង្គោលព្រំប្រទល់ព្រៃលិចទឹកចំនួន១០បង្គោល | | ១៣០០ដុល្លា | | ខែ០១/២០១៨ | ខែ០១/២០១៨ | |
| | • ដាក់ស្លាកសញ្ញាចំនួន៤ស្លាក | | ៨០០ដុល្លា | | ខែ០១/ | ខែ០១/ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១ស្លាក=២០០ដុល្លា | | | | ២០១៨ | ២០១៨ | |
| ៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្រ<br>• របៀបជ្រើសរើសពូជត្រីចិញ្ចឹម<br>• ចំនួនត្រីដែលត្រូវដាក់ចិញ្ចឹម<br>• រៀបចំ បៃ<br>• របៀបអោយចំណី<br>• របៀបថែរក្សា និងព្យាបាល<br>• របៀតតាមដានត្រួតពិនិត្យ<br>• ជ្រើសរើសពេលវេលាសមស្របក្នុងការប្រមូលផល | • សមាជិកគ្រួសារមួយចំនួនត្រូវបានជ្រើសរើសសម្រាប់ចិញ្ចឹមត្រីក្នុងបៃ<br>• កូនត្រីប្រានិងត្រីអណ្តែងចំនួន ៦០០០០កូន នឹងត្រូវផ្តល់អោយចំនួន៥០ គ្រួសារ<br>• រកប្រាក់ចំណូលជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយការធ្វើនេសាទត្រីពីធម្មជាតិ | ៣០០០ដុល្លា | សហគមន៍<br>ផលផល<br>អង្គការដៃគូ | ២០១៨ | ២០២០ | |
| ៦.ផែនការបណ្តុះបណ្តាល | • រៀបចំសិក្ខាសាលាស្តីពីរបៀប<br>• រៀបចំលិខិតរដ្ឋបាល<br>• សរសេររបាយការណ៍<br>• សរសេរកំណត់ហេតុ<br>• ជំនាញសម្របសម្រួល<br>• ជំនាញដោះស្រាយទំនាស់ក្នុងសហគមន៍ | • គណៈកម្មការ សមាជិកសហគន៍យល់ដឹងអំពីផ្នែករដ្ឋបាល និងការគ្រប់គ្រងចាត់ចែងថវិកាក្នុងការអនុវត្តជាក់ស្តែង<br>• កាត់បន្ថយទំនាស់ក្នុងសហគមន៍ | ២៥០០ដុល្លា | អង្គការដៃគូ<br>ជំនាញជលផល | ២០១៨ | ២០២០ | |
| ៧.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | • ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ប្រាក់សមាជិកភាព<br>• ប្រមូលភាគទានសមាជិកសហគមន៍នេសាទ១០០០៛/ម្នាក់ | • ថវិកាដែលបានមកពីសមាជិក អ្នកមិនមែនជាសមាជិកសហគមន៍ អ្នកមកពីខាងក្រៅនិងជំនួយមកពីរាជរដ្ឋាភិបាល អង្គការដៃគូនានា នឹងត្រូវបានប្រើប្រាស់សម្រាប់ដំណើរការអភិវឌ្ឍន៍សហគមន៍នេសាទ | ៥១ដុល្លា | សមាជិក<br>សហគមន៍ | ខែមករា/<br>២០១៨ | ខែធ្នូ/២០២០ | សមាជិក<br>២០៤នាក់ |
| | • ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ ២០០០៛/ម្នាក់ | | ៣០៦ដុល្លា | សមាជិក<br>សហគមន៍ | ២០១៨ | ២០២០ | |
| | • ប្រមូលថវិកាក្នុងតំបន់មិនមែនជាសមាជិកសហគមន៍នេសាទ ៤.០០០៛/ម្នាក់ | | | ប្រជាពលរដ្ឋក្នុងភូមិមិនមែនជាសមាជិកសហគមន៍ | ២០១៨ | ២០២០ | |
| | • ប្រមូលថវិកាមកពីខាងក្រៅសហគមន៍ ៨.០០០៛/ម្នាក់ | | | ប្រជាពលរដ្ឋមកពីក្រៅភូមិ | ២០១៨ | ២០២០ | |

## តារាងកម្មវិធីការងារផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ចារុះ ឆ្នាំ (២០១៨-២០២០)

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៨ | | | | | | | | | | | | ២០១៩ | | | ២០២០ | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | ...... | ធ្នូ | មករា | ...... | ធ្នូ |
| **១.ការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | |
| ១.១ ផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទ | | | | | √ | | | | | | | | | √ | | | √ | |
| ១.២ ត្រួតពិនិត្យ តាមដានការប្រើប្រាស់ឧបករណ៍ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| **២.ផែនការកែលម្អដែននេសាទ** | | | | | | | | | | | | | | | | | | |
| ២.១ ស្វែងរកអ្នកជួយឧបត្ថម្ភ | √ | | | | | | | | | | | | √ | | | √ | | |
| ២.២ ធ្វើការសិក្សាលើទីតាំងនិងទំហំដែលត្រូវស្តារ | | √ | | | | | | | | | | | | √ | | | √ | |
| ២.៣ ចាប់ផ្តើមអនុវត្តការស្តារព្រែក | | | √ | √ | | | | | | | | | | √ | | | √ | |
| **៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | |
| ៣.១ ស្វែងរកអ្នកជួយឧបត្ថម្ភ | √ | √ | | | | | | | | | | | | | | | | |
| ៣.២ បោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស | | | | | √ | √ | | | | | | | | | | | | |
| ៣.៣ ដាក់ស្លាកសញ្ញា | | | | | √ | √ | | | | | | | | | | | | |
| ៣.៤ ដាក់ជម្រកត្រីសិប្បនិម្មិត | | | | √ | √ | | | | | | | | | | | | | |
| ៣.៥ សាងសង់ស្នាក់ការល្បាត | | √ | √ | √ | √ | √ | √ | √ | √ | | | | | √ | | | √ | |
| ៣.៦ ល្បាតប្រចាំការនៅកន្លែងអភិរក្ស | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| **៤.ផែនការគ្រប់គ្រងនិងដាំព្រៃលិចទឹក** | | | | | | | | | | | | | | | | | | |
| ៤.១ ប្រជុំផ្សព្វផ្សាយ | √ | | | | | | | | | | | | √ | | | √ | | |
| ៤.២ ស្វែងរកអ្នកជួយឧបត្ថម្ភ | √ | | | | | | | | | | | | √ | | | √ | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤.៣ ដាំកូនឈើ | | | | | | √ | | | | | | | | √ | | | √ | |
| ៤.៤ បោះបង្គោលព្រំប្រទល់ព្រៃលិចទឹក | √ | | | | | | | | | | | | √ | | | √ | | |
| ៤.៥ ដាក់ស្លាកសញ្ញា | √ | | | | | | | | | | | | √ | | | √ | | |
| **៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | |
| ៥.១ ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត | √ | | | | | | | | | | | | √ | | | √ | | |
| ៥.២ ជ្រើសរើសពូជត្រីចិញ្ចឹម | √ | | | | | | | | | | | | √ | | | √ | | |
| ៥.៣ ចំនួនត្រីដែលត្រូវដាក់ចិញ្ចឹម | | √ | | | | | | | | | | | | √ | | | √ | |
| ៥.៤ រៀបចំបៃ | | √ | | | | | | | | | | | | √ | | | √ | |
| ៥.៥ របៀបអោយចំណី | | √ | √ | √ | √ | √ | | | | | | | | √ | | | √ | |
| ៥.៦ របៀបថៃរក្សានិងព្យាបាល | | √ | √ | √ | √ | √ | | | | | | | | √ | | | √ | |
| ៥.៧ តាមដានត្រួតពិនិត្យ | | √ | √ | √ | √ | √ | | | | | | | | √ | | | √ | |
| ៥.៨ ជ្រើសរើសពេលវេលាសមស្របដើម្បីប្រមូលផល | | | | | | √ | | | | | | | | √ | | | √ | |
| **៦.ផែនការបណ្តុះបណ្តាល** | | | | | | | | | | | | | | | | | | |
| ៦.១ របៀបរៀបចំលិខិតរដ្ឋបាល | | | | | | | | | | | | | | | | | | |
| ៦.២ របៀបសរសេររបាយការណ៍ | | | √ | √ | | | | | | | | | √ | √ | | √ | √ | |
| ៦.៣ របៀបសរសេរកំណត់ហេតុ | | | √ | √ | | | | | | | | | √ | √ | | √ | √ | |
| ៦.៤ ជំនាញសម្របសម្រួល | | | √ | √ | | | | | | | | | √ | √ | | √ | √ | |
| ៦.៥ របៀបដោះស្រាយទំនាស់ក្នុងសហគមន៍ | | | √ | √ | | | | | | | | | √ | √ | | √ | √ | |
| **៧.ផែនការថវិកាទ្រទ្រង់ការអភិវឌ្ឍន៍ ស.ន** | | | | | | | | | | | | | | | | | | |
| ៧.១ ផ្សព្វផ្សាយជ្រើសរើសសមាជិកសហគមន៍ | √ | | | | | | | | | | | | √ | | | √ | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៧.២ ប្រមូលប្រាក់ភាគទានសមាជិកសហគមន៍ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៧.៣ ប្រមូលប្រាក់ភាគទានប្រចាំឆ្នាំពីសមាជិក ស.ន | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៧.៤ ប្រមូលថវិកាពីអ្នកនៅក្នុងតបន់តែមិនមែនជាសមាជិក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៧.៥ ប្រមូលថវិកាពីអ្នកមកពីខាងក្រៅសហគមន៍ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

សូមគោរពជូន
លោកមេឃុំ
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ ... ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័កព.ស ២៥៦២
... ថ្ងៃទី ២៣ ខែ ... ឆ្នាំ២០១៨
ប្រធានគណៈកម្មការសហគមន៍នេសាទ
ទាន់ៈ

លេខ 6556

បានឃើញនិងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលកណ្តៀង
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័កព.ស ២៥៦២
រាំងទិល ថ្ងៃទី ២៣ ខែ ... ឆ្នាំ២០១៨
**មេឃុំរាំងទិល**

បានឃើញនិងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលក្រគរ
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័កព.ស ២៥៦២
កណ្តៀង ថ្ងៃទី ២៣ ខែ ... ឆ្នាំ២០១៨
**នាយសង្កាត់រដ្ឋបាលជលផលកណ្តៀង**

បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ក្រគរ ថ្ងៃទី ២៣ ខែ ... ឆ្នាំ២០១៨
**នាយផ្នែករដ្ឋបាលជលផលក្រគរ**

លេខ ...

បានឃើញនិងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ពោធិ៍សាត់ ថ្ងៃទី ២៧ ខែ ... ឆ្នាំ២០១៨
**នាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់**

**គុំ វិមល**

លេខ ...

បានឃើញនិងគោរពជូន
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"
ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ពោធិ៍សាត់ ថ្ងៃទី ៣០ ខែ ... ឆ្នាំ២០១៨
**ប្រធានមន្ទីរ**
**កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់**

**ឡាយ_វិសិដ្ឋ**

លេខ ...

បានឃើញនិងឯកភាព
ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៨
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**